សេចក្តីជូនដំណឹងដ៏សំខាន់ទៅកាន់គ្រួសារអាណាព្យាបាលទោល

厚生労働省 Ministry of Health, Labour and Welfare

# សេចក្តីណែនាំស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភបណ្តោះអាសន្នពិសេសសម្រាប់គ្រួសារអាណាព្យាបាលទោល

## ផ្តល់ប្រាក់ឧបត្ថម្ភដើម្បីគាំទ្រដល់គ្រួសារអាណាព្យាបាលទោល!

## 1. ការផ្តល់ជាមូលដ្ឋាន

ផ្តល់ជូនអ្នកគ្រួសារអាណាព្យាបាលទោលដែលកំពុងទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមកូន※1

### ● អ្នកដែលត្រូវទទួលប្រាក់ឧបត្ថម្ភ

■អ្នកដែលអាចបំពេញលក្ខខណ្ឌណាមួយពី①～③ដូចខាងក្រោម

① អ្នកដែលត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនក្នុងខែមិថុនា ឆ្នាំ២០២០

② អ្នកដែលកំពុងទទួលប្រាក់សោធននិវត្តសាធារណៈ※2 ហើយត្រូវបានបញ្ឈប់ការផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនទាំងអស់ក្នុងខែមិថុនា ឆ្នាំ២០២០※3

③ អ្នកដែលមានកម្រិតដូចអ្នកកំពុងទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមកូនជាចំណូល ដែលមានភាពបម្រែបម្រួលខ្លាំងក្នុងជីវភាពគ្រួសារដោយរងផលប៉ះពាល់ពីជម្ងឺឆ្លងមេរោគកូរ៉ូណា

※1 «អ្នកចិញ្ចឹមបីបាច់»ដែលមានចែងក្នុងច្បាប់ចិញ្ចឹមកូនក៏ស្ថិតក្នុងរង្វង់នេះដែរ

※2 ដូចជាប្រាក់សោធននិវត្តន៍គ្រួសារអ្នកដែលបានទទួលមរណភាព ប្រាក់សោធននិវត្តន៍ពិការភាព ប្រាក់សោធននិវត្តន៍ចាស់ជរា ប្រាក់សោធននិវត្តន៍គ្រោះថ្នាក់ការងារ ប្រាក់ឧបត្ថម្ភគ្រួសារអ្នកបានទទួលមរណៈ ។ល។

※3 មិនត្រឹមតែអ្នកដែលត្រូវបានទទួលស្គាល់ថាមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភចិញ្ចឹមកូនទេ អ្នកដែលស្នើសុំប្រាក់ឧបត្ថម្ភចិញ្ចឹមកូន ហើយត្រូវបានប៉ាន់ប្រមាណថាមានការផ្អាកការផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនក្នុងខែមិថុនា ឆ្នាំ២០២០ក្នុងទឹកប្រាក់ទាំងអស់ ឬទឹកប្រាក់មួយផ្នែក។

### ● ចំនួនទឹកប្រាក់ផ្តល់

១គ្រួសារ**៥ម៉ឺនយេន** ចាប់ពីកូនទី២ទៅ១នាក់**៣ម៉ឺនយេន**

## 2. ការផ្តល់បន្ថែម

ផ្តល់ជូនអ្នកដែលមានចំណូលធ្លាក់ចុះ និងមានបម្រែបម្រួលជីវភាពខ្លាំងដោយសារផលប៉ះពាល់នៃជម្ងឺឆ្លងមេរោគកូរ៉ូណា

### ● អ្នកដែលត្រូវទទួលប្រាក់ឧបត្ថម្ភ

ក្នុងចំណោមអ្នកស្ថិតក្នុងចំណុច① ឬ ② ដែលជាមូលដ្ឋាននៃការផ្តល់ខាងលើ អ្នកដែលមានចំណូលធ្លាក់ចុះ និងមានបម្រែបម្រួលជីវភាពខ្លាំងដោយសារផលប៉ះពាល់នៃជម្ងឺឆ្លងមេរោគកូរ៉ូណា

### ● ចំនួនទឹកប្រាក់ផ្តល់

១គ្រួសារ៥ម៉ឺនយេន

**នីតិវិធីនៃការធ្វើបែបបទមាននៅទំព័រខាងក្រោយ។ សូមបញ្ជាក់ឲ្យបានច្បាស់។**

# បែបបទនៃការផ្តល់ប្រាក់ឧបត្ថម្ភ

## អ្នកដែលត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនក្នុងខែមិថុនា ឆ្នាំ២០២០ (ទំព័រខាងមុខ អ្នកដែលស្ថិតក្នុងចំណុច 1. ①)

▶ **ការផ្តល់ជាមូលដ្ឋានគឺមិនចាំបាច់ស្នើសុំទេ។**

▶ **នៅកំឡុងខែសីហា** នឹងផ្ទេរប្រាក់ទៅគណនីផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូនសម្រាប់ខែមិថុនា ឆ្នាំ២០២០។

【សូមប្រុងប្រយ័ត្ន】

※ **ករណីមិនចង់បានប្រាក់ឧបត្ថម្ភទេ លិខិតជូនដំណឹងដែលបានផ្ញើទៅសូមផ្ញើត្រឡប់មកវិញ។**

※ ប្រសិនបើឈប់ប្រើគណនីដែលបានកំណត់សម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភចិញ្ចឹមកូន អាចនឹងបណ្តាលឲ្យមានឧបសគ្គសម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភ ដូច្នេះសូមធ្វើបែបបទផ្លាស់ប្តូរគណនីផ្ទេរប្រាក់ដែលបានកំណត់។

▶ **ការផ្តល់បន្ថែមចាំបាច់ត្រូវស្នើសុំ។**

▶ ផ្តុំផ្សំនឹងពេលពិនិត្យស្ថានភាពបច្ចុប្បន្ន(ខែសីហា)តាមពេលកន្លង អនុវត្តវិធីងាយៗក្នុងការស្នើសុំថាប្រាក់ចំណូលកំពុងថយចុះ។ ពិនិត្យខ្លឹមសារស្នើសុំរួចនឹង**ព្យាយាមផ្ទេរ**ប្រាក់**ឲ្យបានឆាប់**។

## អ្នកស្ថិតក្រៅចំណុចនោះ (ទំព័រខាងមុខ អ្នកដែលស្ថិតក្នុងចំណុច 1. ②、③)

▶ **ចាំបាច់ត្រូវស្នើសុំទាំងការផ្តល់ជាមូលដ្ឋាន/ការផ្តល់បន្ថែម**(សម្រាប់តែ1.②)

▶ សូមបំពេញគណនីផ្ទេរប្រាក់នៅលិខិតស្នើសុំ ហើយ**ផ្ញើតាមប្រៃសណីយ៍** ឬយកទៅដាក់**ផ្ទាល់នៅកន្លែងទទួលពាក្យ**ក្នុងតំបន់កំពុងរស់នៅដោយភ្ជាប់ជាមួយឯកសារចាំបាច់។

▶ ចំពោះអ្នកដែលបំពេញគ្រប់លក្ខខណ្ឌផ្តល់ប្រាក់ឧបត្ថម្ភ ក្រោយពិនិត្យខ្លឹមសារស្នើសុំរួចនឹង**ព្យាយាម**ផ្ទេរប្រាក់**ឲ្យបានឆាប់**។

គ្រួសារដែលមានអាណាព្យាបាលទោល

**(1)បែបបទស្នើសុំប្រាក់ឧបត្ថម្ភ**

①សូមផ្ញើឯកសារតាមប្រៃសណីយ៍ ឬមកកន្លែងទទួលពាក្យដោយផ្ទាល់ក្នុងតំបន់កំពុងរស់នៅ។

**(2)ផ្ទេរប្រាក់ចូលគណនីដែលបានកំណត់**

② យោងតាមលិខិតស្នើសុំដែលបានដាក់មក ក្រោយការវិនិច្ឆ័យថាគ្រប់លក្ខខណ្ឌផ្តល់ប្រាក់ឧបត្ថម្ភ នឹងមានការផ្ទេរប្រាក់ជូន។

ក្នុងតំបន់កំពុងរស់នៅ

## កន្លែងសួរព័ត៌មាន

មជ្ឈមណ្ឌលទំនាក់ទំនង «ការផ្តល់ប្រាក់ឧបត្ថម្ភបណ្តោះអាសន្នពិសេសសម្រាប់គ្រួសារដែលមានអាណាព្យាបាលទោល»

**0120-400-903** (ម៉ោងទទួល ថ្ងៃធម្មតា 9:00～18:00)

○ព័ត៌មានលម្អិតស្តីពីរបៀបស្នើសុំ សូមសួរទៅកាន់កន្លែងទទួលបន្ទុក«ការផ្តល់ប្រាក់ឧបត្ថម្ភបណ្តោះអាសន្នពិសេសសម្រាប់គ្រួសារអាណាព្យាបាលទោល»នៅក្នុងភូមិឃុំសង្កាត់ឬក្រុងដែលអ្នកកំពុងរស់នៅ។

❗ តាមរយៈ«ការផ្តល់ប្រាក់ឧបត្ថម្ភបណ្តោះអាសន្នពិសេសសម្រាប់គ្រួសារអាណាព្យាបាលទោល»

**សូមប្រុងប្រយ័ត្ន«ការឆបោកឲ្យផ្ទេរប្រាក់»និង«ការលួចយកព័ត៌មានផ្ទាល់ខ្លួន»។**

ករណីមានទទួលទូរស័ព្ទឬបញ្ញើប្រៃសណីយ៍គួឲ្យសង្ស័យថា(ជាបុគ្គលិក)មកពីភូមិឃុំសង្កាត់ឬខេត្តក្រុង នឹងក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព ទៅកាន់ផ្ទះនិងកន្លែងធ្វើការ សូមទាក់ទងទៅកាន់ភូមិឃុំសង្កាត់ដែលអ្នកកំពុងរស់នៅនិងប៉ុស្តិ៍ប៉ូលិស(ឬទូរស័ព្ទពិសេសសម្រាប់ពិគ្រោះជាមួយប៉ូលិស(#9110))។